# មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0022

## សម្ភាសន៍ជាមួយឈ្មោះ មាន ពៅ ភេទប្រុស អាយុ៨៩ឆ្នាំ

## មុខងាររជនាន់ខ្មែរក្រហម“យោធា”

## មុខងារបច្ចុប្បន្ន“កសិករ”

## ស្រុកកំណើតនៅភូមិដាំថ្នាំ ឃុំអង្គមាស ស្រុកឈូក ខេត្តកំពត

## រស់នៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០ៈ៤២ៈ២៣

## ១៥ទំព័រ

វណ្ណៈ: ចឹងមុនហ្នឹងធ្វើការសម្ភាសន៍បងខ្ញុំធ្វើការណែនាំខ្លួនខ្ញុំសិន ។

ពៅ : បាទ ។

វណ្ណៈ: ខ្ញុំឈ្មោះសុខ វណ្ណៈមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកនេះចង់ដឹងរឿងរ៉ាវនៅស្រុកម៉ាឡៃ ពីមុនមកឮថាមានចលនាតស៊ូមានព្រៃច្រើន មានព្រៃខ្លាព្រៃដំរីយ៉ាងម៉េចនោះ ។

ពៅ : បាទ ។

វណ្ណៈ: កាលហ្នឹងឮថាមិនទាន់មានផ្លូវទេ ។

ពៅ : បាទ ។

វណ្ណៈ: ហើយចង់ដឹងរឿងប្រវត្តិផ្ទាល់ខ្លួនរបស់បងខ្លះៗ ដែលធ្លាប់ឆ្លងកាត់កន្លងមកតាំងពីតូច ។

ពៅ : បាទ ។

វណ្ណៈ: ចឹងប្រវត្តិទាំងអស់ហ្នឹងខាងខ្ញុំចង់យកទៅចងក្រងជាសៀវភៅអីហ្នឹង តើបងអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងឮបានទេ?

ពៅ : ចុះមានអី ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះបង តើបងឈ្មោះអីដែរ?

ពៅ : ខ្ញុំឈ្មោះមាន ពៅ ។

វណ្ណៈ: បងអាយុប៉ុន្មាន?

ពៅ : អាយុ៨៩ ។

វណ្ណៈ: ចឹងឪពុកបងឈ្មោះអី?

ពៅ ៖ ឪពុកឈ្មោះ មាន ខន ។

វណ្ណៈ៖ ចុះម្ដាយ?

ពៅ ៖ ម្ដាយឈ្មោះ លី សិ ។

វណ្ណៈ៖ ចឹងគាត់សព្វថ្ងៃនៅរស់ទាំងអស់?

ពៅ ៖ គាត់ស្លាប់អស់ហើយ ស្លាប់សម័យប៉ីឆ្នាំអស់ហើយ ។

វណ្ណៈ៖ ចឹងបងមានគ្រួសារឈ្មោះអី?

ពៅ ៖ ឈ្មោះ អ៊ុច គា ។

វណ្ណៈ៖ មានកូនប៉ុន្មាននាក់?

ពៅ ៖ មានកូន៤នាក់ស្រី២ប្រុស២ ។

វណ្ណៈ៖ ស្រុកកំណើតនៅភូមិអីមានចាំទេ?

ពៅ ៖ ភូមិដាំថ្នាំ ឃុំអន្លុងមាស ស្រុកឈូក ខេត្តកំពត ។

វណ្ណៈ៖ ឥឡូវនៅភូមិ?

ពៅ ៖ ឥឡូវនៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ៖ ចឹងសព្វថ្ងៃបងប្រកបមុខរបរអ៊ីទៅ?

ពៅ ៖ សព្វថ្ងៃធ្វើស្រែចំការខ្លះទៅ ហើយកូនលក់ដូរបន្តិចបន្តួចនៅផ្សារ ។

វណ្ណៈ៖ ចឹងខ្ញុំចង់ដឹងប្រវត្តិរបស់បងចេញពីផ្ទះនៅពេលណា ហើយរៀនបានត្រឹមណា?

ពៅ ៖ ខ្ញុំរៀនបានថ្នាក់ទី៩ចាស់ ក្រោយមកខ្ញុំវ៉ាកងសម្រាកហើយបានសុំម្ដាយឪពុកចេញពីខេត្តកំពតហ្នឹងទៅលេងផ្ទះតា ដល់ទៅលេងផ្ទះតាទៅទទួលកងកំលាំងហ្នឹងកាត់ស្ពានកំពតយើងហ្នឹង ។

វណ្ណៈ៖ បាទ ។

ពៅ ៖ អាស្ពានឥឡូវមានស្គាល់អត់?

វណ្ណៈ៖ អត់ស្គាល់ផង ។

ពៅ ៖ បាទ!កាលនោះស្ពានឥឡូវគេកាត់ផ្ដាច់ធ្លាក់ទៅក្នុងព្រែកទៅណាស់ ស្ពានធំណាស់ ស្ពានឆ្លងកាត់ទីក្រុងខេត្តកំពតហ្នឹងណាស់ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ដល់កាត់ដាច់ទៅខ្ញុំក៏មិនអាចទាក់ទងឪពុកម្ដាយបានតាំងពីឆ្នាំ១៩៧២ម្ល៉េះ ដល់ចឹងទៅខ្ញុំក៏រស់នៅជាមួយបងជីដូននៅបឹងទូកស្រុកកំពតខាងលិចណាស់ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ដល់ពេលចឹងទៅរស់នៅជាមួយជីដូនចឹងទៅធ្វើចំការពុះអូសលក់ចឹងទៅ រួចពុះឬស្សីវែងជាលបដាក់ត្រីម ត្រីមសមុទ្រ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ក៏រកស៊ីជាមួយគាត់ជាមួយកូនគាត់ចឹងទៅ ដល់មានថ្ងៃមួយនោះគេមកចាប់ខ្ញុំយកទៅក៏បណ្ដើរខ្ញុំកាលហ្នឹងមានតែអាវខ្ទីមួយខោខ្ទីមួយចេញពីបឹងទូកចឹងទៅ គេហៅព្រៃទប់ក៏ចេញពីព្រៃទប់ហ្នឹងមកខាងតាកែនកោះស្លាស្រកានាគហ្នឹង ក៏បានរស់នៅជាមួយបងៗហ្នឹងរហូតទៅដល់ឆ្នាំ៧៤ គេបានវាយរំដោះរោងចក្រនៅខេត្តកំពតហ្នឹង កាលហ្នឹងខ្ញុំមិនទាន់ចេះវៃចេះតប់គេដែរ កាលសម័យរំដោះជាតិហ្នឹងក៏នៅបរទេះសេះដឹកស្បៀងជាអង្ករជាសាច់ជាត្រីងៀតអីហ្នឹង ដល់កងទ័ពសមរភូមិមុខចឹងទៅ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ដល់រំដោះហើយនៅឆ្នាំ៧៥ ក៏បានចូលកងកុមារចឹងទៅគេឲ្យយាមការពារធូរេនទៅទឹកឈូ គេហៅចំការយក់ឡាយៗ ក៏នៅមើលធូរេនហ្នឹងទៅ ដល់រួចពីហ្នឹងមកគេឲ្យទៅធ្វើស្រែចំការចឹងទៅតាមការដឹកនាំរបស់ថ្នាក់ដឹកនាំហ្នឹង ដល់ធំបន្តិចទៅក៏បានចូលកងចល័តក៏នៅធ្វើស្រែលើកប្រឡាយលើកភ្លឺជាមួយគេជាមួយឯងទៅ រហូតដល់ពេលឆ្នាំ៧៩ នៅពេលកងទ័ពវៀតណាមវៃចូលចឹងមក ក៏ពួកខ្ញុំហ្នឹងនាំគ្នារត់មក កាលហ្នឹងចេះតែរត់ទៅ មានជិះឡានដល់អស់ឡានចេះតែដើរមកទៀត មិនដឹងជាឆ្លងកាត់ស្រុកណាខ្លះទេ មិនសូវស្គាល់ទេ មកដល់លិចមកក៏ចេះតែមកៗ ក៏ធ្លាក់មកដល់នេះឯងព្រំដែននេះតែម្ដង បានមកដល់ព្រំដែនឆ្នាំ៧៩-៨០នេះ ការរស់នៅព្រំដែនមានព្រៃអីសព្វគ្រប់បែបយ៉ាង វាមិនវាលដូចយើងសព្វថ្ងៃទេ កាលហ្នឹងព្រៃឈើវាមានច្រើន មានសត្វមានអី ធម្មតាទេក្នុងព្រៃវាមិនមែនអត់ទេសត្វនោះ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ សត្វតូចសត្វធំនោះវាតែងតែមានហើយ និងក្រោយមកទៀតបានព្រៃឈើហ្នឹង កាប់យកមកធ្វើផ្ទះធ្វើសំបែងទៅ សព្វថ្ងៃមានសន្សំក៏ដោយសារព្រៃឈើហ្នឹងដែរ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរបញ្ជាក់ឡើងវិញថា បងមានបងប្អូនប៉ុន្មាននាក់កាលហ្នឹង?

ពៅ ៖ ខ្ញុំមានបងប្អូនពីរនាក់ទេ បែកគ្នាពេលហ្នឹងឯង ។

វណ្ណៈ៖ ចឹងម្នាក់ទៀតនៅណា?

ពៅ ៖ ម្នាក់ទៀតនៅជាប់ជាមួយឪពុកម្ដាយ នៅកំពតហ្នឹង ។

វណ្ណៈ៖ ចឹងកាលឆ្នាំ៧២ហ្នឹងបងចូលទៅនៅតូច?

ពៅ ៖ បាទ ។

វណ្ណៈ: ចឹងចូលទៅជួយរកស្បៀងឲ្យបងៗខាងមុខចឹង?

ពៅ : បាទ ។

វណ្ណៈ: ចឹងឆ្នាំ៧៥ ខ្មែរក្រហមចូលដល់ភ្នំពេញ?

ពៅ : អាហ្នឹងរំដោះហើយ ។

វណ្ណៈ: ចឹងពេលរំដោះហើយបងនៅណា?

ពៅ : ខ្ញុំនៅកុមារ ។

វណ្ណៈ: កុមារនៅណា?

ពៅ : កុមារនៅកំពត ។

វណ្ណៈ: ចឹងអត់មានមកភ្នំពេញទេ?

ពៅ : អត់មានមកភ្នំពេញទេ ។

វណ្ណៈ: ចឹងនៅមើលចំការធូរេន?

ពៅ : បាទ ។

វណ្ណៈ: ចឹងនៅរហូតដល់ឆ្នាំ៧៩?

ពៅ : បាទ ។

វណ្ណៈ: ចឹងនៅពេលឆ្នាំ៧៩ហើយ ហេតុអីបានជាបងមិនរត់ទៅរកផ្ទះយ៉ាងម៉េចបានជាបងរត់មកព្រំដែនវិញ?

ពៅ : កាលហ្នឹងឃើញគេមកភ្លូកទឹកភ្លូកដីចេះតែមកទៅ ។

វណ្ណៈ: ចឹងមានន័យថាមកតាមគេ?

ពៅ : បាទ! ដូចថាយើងនិយាយថាមកតាមថ្នាក់ដឹកនាំ ថាមកជាកងចឹងមក ។

វណ្ណៈ: ចឹងកាលហ្នឹងអត់មានគិតថា បែកហើយចង់ទៅរកឪពុកម្តាយ?

ពៅ : អត់មានគិតឃើញចឹងសោះ ។

វណ្ណៈ: ចឹងកាលបងនៅធ្វើការនៅចំការធូរេនហ្នឹងហូបចុកយ៉ាងម៉េចដែរ?

ពៅ : ហូបចុកធម្មតា បើមានបបរក៏ហូបឆ្អែតដែរ ។

វណ្ណៈ: ចឹងកាលជំនាន់ហ្នឹងបងមានដឹងថាមានការចាប់មនុស្សអីទេ?

ពៅ : នៅកុមារហ្នឹងដូចជាមិនឃើញអីទេ ។

វណ្ណៈ: ចឹងនៅកងកុមារហ្នឹងមានគ្នាច្រើនទេ?

ពៅ : នៅកន្លែងកុមារមានមនុស្សច្រើនដែរ ។

វណ្ណៈ: ចឹងអត់មានផ្លាស់ប្តូទៅណាទេ?

ពៅ ៖ អត់មានទៅណាទេ ពួកខ្ញុំព្រឹកឡើងយើងទាញចបទៅចូកស្មៅធូរេនស្មៅសាវម៉ាវ ។

វណ្ណៈ៖ ចឹងកាលដែលបងរត់មកដល់ព្រំដែននេះត្រូវរយៈពេលប៉ុន្មានទៅ?

ពៅ ៖ កាលរត់ដូចជាមិនដល់មួយខែទេ ។

វណ្ណៈ៖ ចឹងកាលហ្នឹងបងដើរប្រមួយជិះឡាន?

ពៅ ៖ មុនដំបូងជិះឡាន ជិះកាត់ណាទេ កាត់កំពង់ស្ពឺឬណាទេ វាមិនសូវស្គាល់ដែរ គេហៅម្ដុំលាចអី
នះ ដល់ឡានអស់សាំងទៅនាំគ្នាដើរ ។

វណ្ណៈ៖ ចឹងកាលធ្វើដំណើរតាមផ្លូវចឹងមានឃើញប្រជាជនយើងស្លាប់តាមផ្លូវអីដែរ?

ពៅ ៖ កាលមកមានឃើញដែរ មានឈឺមានអី តែស្លាប់មិនបានឃើញទេ តែឃើញមានឈឺ ។

វណ្ណៈ៖ ចឹងមានប្រជាជនច្រើនទេ?

ពៅ ៖ កាលហ្នឹងមានប្រជាជនមានទ័ពអីចឹង ឃើញប្រជាជនឈឺលើរទេះអីចឹង ។

វណ្ណៈ៖ ចឹងនៅពេលដល់ដំរំដំបូងថា តើកំលាំងខ្មែរក្រហមប្រមូលគ្នាបានឡើងវិញយ៉ាងម៉េច?

ពៅ ៖ ពេលមកដល់ព្រំដែនហ្នឹងមិនទាន់ប្រម៉ែប្រមូលបានដូចថា គ្រឹប ៗ ទេ កាលនោះនៅតាមកងចឹង
អ្នកដឹកនាំនៅពេលនោះដឹងថានៅនោះ ចេះតែប្រមូលគ្នាទៅដឹកនាំចឹងមក ។

វណ្ណៈ៖ បាទ ។

ពៅ ៖ កាលនោះស្បៀងមិនទាន់បានភ្ជាមដែរ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ យើងត្រូវការទាក់ទងខាងក្រោយខ្នងយើងនេះ ទំរាំបានស្បៀងមក ។

វណ្ណៈ៖ ចឹងកាលមកដល់ដំបូងមានរត់ចូលទៅថៃទេ?

ពៅ ៖ អត់ទេ មិនហ៊ានចូលទេ ពួកខ្ញុំនៅហ្នឹងបណ្ដោយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងគេថានៅតំបន់ហ្នឹងព្រៃមើលថ្ងៃមិនចង់ឃើញជាការពិតទេ?

ពៅ ៖ វាមែន យើងចូលទៅព្រៃដុងជ្រៅទៅណាស់ ក្រោយផ្សារកន្ទែងរាងជ្រៅទៅវាមែន ។

វណ្ណៈ៖ ចឹងកាលហ្នឹងគ្មានផ្ទះសំបែងហើយមកនៅក្នុងព្រៃចឹងបងមានអារម្មណ៍ភ័យខ្លាចទេ?

ពៅ ៖ កាលហ្នឹងភ័យខ្លាចចេះតែមានហើយ កាលហ្នឹងយើងនៅមានអាយុស្ទើរ ៗ ដែរ ព្រួសូវស្រួសត្វឃំ
ចឹងគេថាមានសត្វខ្លាអីហ្នឹង ចឹងការខ្លាចចេះតែមានហើយ តែសត្វទាំងនោះមិនដែលមកប៉ះពាល់
ខាំយើងដែរ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមានសត្វដំរីអីទេ?

ពៅ ៖ ដំរីនៅម៉ាឡៃខ្ញុំមិនដែលឃើញទេ តែខ្លា ខ្ទីងអីមានឃើញមែន ឈ្លូស ប្រើសអីមាន ។

វណ្ណៈ៖ ចឹងមានដឹងទេ ថាព្រៃហ្នឹងមានដំរីទេ?

ពៅ : ដូចជាមិនអត់ទេ ព្រោះព្រៃហ្នឹងធំដែលដូចជាមិនអត់ទេ ។

វណ្ណៈ: ចឹងចង់សួរទៅខាងយោធាវិញ មានកងដឹកនាំអីប្រហែលជាឆ្នាំណា?

ពៅ : ចាប់ផ្ដើមប្រមូលកំលាំងហ្នឹងប្រហែលជាឆ្នាំ៨០គត់ដើម៨១អីមានហើយ ។

វណ្ណៈ: ចឹងកាលហ្នឹងចាប់ផ្ដើមវៃជាមួយយួនហើយ?

ពៅ : បាទ!កាលហ្នឹងមានទ្រុងទ្រាយធំហើយអាហ្នឹង មានវៃជាសង្គ្រាមឈ្លប ។

វណ្ណៈ: ចឹងកាលពេលវៃហ្នឹងមានទាហានយួននិងទាហានខ្មែរក្រហមមានស្លាប់ដូចគ្នាឬមួយយ៉ាងម៉េច?

ពៅ : កាលវៃជិតនាន់នោះជាសង្គ្រាមឈ្លបយើងមិនបានឃើញ ហើយយើងក៏អត់មានរបួស កាលហ្នឹងគ្រាន់តែប្រាវៗគេច វៃជាសង្គ្រាមឈ្លបវៃៗដករត់ ។

វណ្ណៈ: ចឹងសម្ភារខ្មែរក្រហមទទួលបានមកពីខាងណា?

ពៅ : កាលហ្នឹងនិយាយឲ្យអស់ទៅ បានមកពីខាងប្រទេសចិនគេជំនួយនិងសម្ភារយើងមកជាប់និងខ្លួនខ្លះទៅ ។

វណ្ណៈ: ចឹងមេដឹកនាំជំបូងចលនានៅខាងហ្នឹងពីណាគេទៅ?

ពៅ : ចឹងនៅហ្នឹងអ៊ំអៀង សារី ហៅអ៊ំវ៉ាន់ ។

វណ្ណៈ: ចឹងដល់មេកងពលមានពីណាគេ?

ពៅ : មេកងពលមានបងសុខ ភាពចឹងទៅ ។

វណ្ណៈ: តែមុនហ្នឹងទៀតពីណាគេ?

ពៅ : មានតូ ហុងដែរ ។

វណ្ណៈ: ចឹងលោកខៀវ សំផនមានមកខាងហ្នឹងទេ?

ពៅ : កាលហ្នឹងអ៊ំខៀវ មានមកម្ដងម្កាលដែរ ថ្នាក់ដឹកនាំមិនអត់ទេ រឿងចុះឡើងនោះ ។

វណ្ណៈ: ចឹងប៉ុល ពតមានមកដែរ?

ពៅ : គាត់មកម្ដងម្កាលដែរ ។

វណ្ណៈ: ចឹងនៅឆ្នាំណាដែលមានទីតាំងរឹងមាំ?

ពៅ : មានទីតាំងមានប្រជាជនអី ខ្ទង់៨៣-៨៤អីហ្នឹងយើងមានហូបចុកត្រឹមត្រូវលែងខ្វះខាតអីហើយ ។

វណ្ណៈ: មានហូបចុកគ្រប់គ្រាន់តែនៅមានច្បាំងគ្នា?

ពៅ : អាហ្នឹងធម្មតាទេ កាលវៃចេះតែមានហើយ ។

វណ្ណៈ: ចឹងនៅនេះប្រជាជនដូចជាទ័ពដែរ?

ពៅ : បាទ ។

វណ្ណៈ:  ចឹងកាលហ្នឹងកាលសម្តេចមកសារតាំងនៅតំបន់នេះប្រហែលជាឆ្នាំណាដែរ?

ពៅ  :  ខ្ញុំដូចជាភ្លេចដែលហើយ  ខ្ញុំមិនសូវចាំទេ  តែរឿងមកពិតជាមកហើយតែខ្ញុំមិនសូវចាំ ។

វណ្ណៈ:  កាលហ្នឹងមកប៉ុន្មានដង?

ពៅ  :  កាលហ្នឹងមកពីរសារ  ដូចជាចង់ភ្លេចហើយដឹងថាសម្តេចឪមក  តែខ្ញុំនៅតែខាងមុខដែរ ។

វណ្ណៈ:  ចឹងបងអត់មានបាននៅចាំការពារសម្តេចទេ?

ពៅ  :  ខ្ញុំបាននៅវគ្គទី១បាននៅឃើញគាត់  ដល់មកវគ្គក្រោយខ្ញុំនៅខាងមុខនោះ ។

វណ្ណៈ:  ចឹងមានឃើញអ្នកកាសែតមកជាមួយទេ?

ពៅ  :  កាលមកវគ្គដំបូងមានឃើញអ្នកកាសែតមកដែរ  ខ្ញុំមិនដឹងជាខាងណាខាងណីទេ  ខ្ញុំមិនបានយល់ដែលទេ  មានកាសែតថៃ  កាសែតបរទេសខាងណាខាងណីអី ។

វណ្ណៈ:  ចឹងកាលមកហ្នឹងគណៈប្រតិភូគេជិះដំរីឬមួយគេជិះឡាន?

ពៅ  :  កាលខ្ញុំឃើញវគ្គទី១ហ្នឹង  ដើរឆ្លងស្ពានយើងមកតាមដីថៃ  ដើរតាមក្រោយមកចូលទៅសាតាំងទៅ ។

វណ្ណៈ:  កាលហ្នឹងមិនទាន់មានមីនច្រើនទេ?

ពៅ  :  កាលហ្នឹងនិយាយរឿងមីនមិនទាន់មានទេ ។

វណ្ណៈ:  ចឹងគេថាមីនមានច្រើននៅស្រុកម៉ាឡៃហ្នឹងពីណាជាអ្នកដាក់?

ពៅ  :  មីនមានច្រើនចូលឆ្នាំ៨៥ហើយទេ  ដាក់ទាំងសងខាង  កាល«ក៥»ដាក់ទាំងបាវ ។

វណ្ណៈ:  ចឹងកាលជំនាន់«ក៥»ចុះមកដល់ហ្នឹងដែរ?

ពៅ  :  ហ្នឹងចុះមកដល់ហ្នឹង  កាលឆ្នាំ៨៥-៨៦ហ្នឹង ។

វណ្ណៈ:  ចឹងបានជាមានស្លាប់ច្រើនដែរខាង«ក៥»?

ពៅ  :  កាល៨៥គេហៅថាវៃដាក់មុងគ្រប ។

វណ្ណៈ:  ចឹងខាង«ក៥»ចុះមកដល់ម៉ាឡៃដែរ?

ពៅ  :  បាទ!មានខ្លះមិនដាក់ដែរ  យកទាំងការ៉ុងដាក់តាមគល់ឈើ  ដល់នេះខ្មែរគ្នាឯងចេះតែយកដាក់ទៅកាលហ្នឹងអ្នក«ក៥»គ្នាលីជញ្ជូនមកដែរ  គរចោលដូចដំបូកចឹង ។

វណ្ណៈ:  ចឹងយើងវៃទប់ទល់ជាមួយយួនរហូតដល់ឆ្នាំ៨៧/យួនដកអស់ហើយ ។

ពៅ  :  បាទ ។

វណ្ណៈ:  ចឹងនៅពេលដែលយើងវៃជាមួយខ្មែរនិងខ្មែរខ្លាំងជាងមុនឬយ៉ាងម៉េច?

ពៅ  :  ថយ  អត់មានអីទ្រុងទ្រាយធំទេ  មានតែថយ ។

វណ្ណៈ:  ចឹងនៅតំបន់ម៉ាឡៃនេះព្រៃនៅឆ្នាំណាចាប់ផ្តើមអស់?

ពៅ ៖ មើលកាលឆ្នាំ៩១-៩២ យើងចាប់ផ្ដើមបរសត្វចូល ។

វណ្ណៈ៖ បើកបរសត្វចូលយ៉ាងម៉េច?

ពៅ ៖ បើកបរសត្វដូចជាយើងនិយាយថា ក្រុមហ៊ុន ចៅកែចូលមកកាត់ឈើអីចឹងទៅណាស់ ។

វណ្ណៈ៖ ចឹងមកពីខាងណា?

ពៅ ៖ មកពីខាងថៃ ។

វណ្ណៈ៖ ចឹងមានន័យថាឆ្នាំហ្នឹងជិតអស់ហើយ?

ពៅ ៖ បាទ! ក្រោយមកចេះតែស្បើយទៅៗ ។

វណ្ណៈ៖ ចឹងនៅពេលដែលកងទ័ពយួនដកចេញហើយនៅសល់ខ្មែរនិងខ្មែរវៃគ្នា នៅពេលហ្នឹងចិនជំនួយមកទៀតដែរ?

ពៅ ៖ ឈប់ហើយកាលហ្នឹង ។

វណ្ណៈ៖ ចឹងបានជាកំលាំងខ្មែរក្រហមកាត់ឈើខ្លះដើម្បីដោះដូបានស្បៀង?

ពៅ ៖ បាទ! អាចយកមកដោះស្រាយខ្លះ ។

វណ្ណៈ៖ ចឹងពេលដែលវៃគ្នាឯងចិនឈប់ហើយ?

ពៅ ៖ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងបងមានដឹងថា តើថៃមានផលប្រយោជន៍អីជាមួយខ្មែរក្រហមបានជានៅពេលដែលកំលាំងខ្មែរក្រហមចាញ់អាចរត់ចូលដីថៃអីបាន?

ពៅ ៖ ចឹងបើតាមខ្ញុំយល់យើងនៅពីមុខវា យើងជារបងការពារឲ្យដីវាដែរ ឬមួយយើងជ្រោកកោនដីវាឬមួយយើងបាក់ខាងកំលាំងខ្មែរក្រហមរត់ចូលទៅគេមានជំរំទុកដាក់យើងទៅ តែទៅកំលាំងប្រជាជននិងកំលាំងទ័ពជារនាំងការពារដល់គេសុខសាន្ត ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ចឹងមានផលប្រយោជន៍វាមួយចំនួនដែរ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ មិនអាចប៉ះពាល់ដល់គេ ។

វណ្ណៈ៖ ចឹងមានបងប្អូនយើងដាច់ដៃជើងច្រើនទេ នៅតំបន់ម៉ាឡៃនេះ?

ពៅ ៖ មានពិការច្រើន ស្រុកម៉ាឡៃយើងនេះពិការច្រើនណាស់ ។

វណ្ណៈ៖ ដោយសារតែសង្គ្រាម?

ពៅ ៖ ដោយសារសង្គ្រាមផង ទី២អស់លោកទៅកាប់ព្រៃដើម្បីយកដីធ្វើចំការ វាមានការប៉ះពាល់តាមដីចាស់ៗដែលតំបន់យើងធ្លាប់ប្រយុទ្ធគ្នាហ្នឹង មានគ្រាប់នៅចឹងគ្រោះថ្នាក់ជាបន្តបន្ទាប់ទៅ ។

វណ្ណៈ  បាទ ។

ពៅ  :  យកដីធ្វើការគិតថាដីហ្នឹងមិនមានអីទេ  ចេះតែលូកចេះតែកាប់ទៅក៏ដុះឡើងទៅ ។

វណ្ណៈ  ចឹងមានគ្រោះថ្នាក់ច្រើនដែរ?

ពៅ  :  បាទ!ដូចជាខ្ញុំដាច់ជើងមួយកំណាត់ហ្នឹងចឹងទៅ ។

វណ្ណៈ  ចឹងបងដាច់ជើងនៅឆ្នាំណាដែរ?

ពៅ  :  ខ្ញុំដាច់ជើងនៅឆ្នាំ១៩៨៧ ។

វណ្ណៈ  ចឹងឆ្នាំ៨៧?

ពៅ  :  ខែ៧  ថ្ងៃ៧  ឆ្នាំ១៩៨៧ ។

វណ្ណៈ  ចឹងបងចាំច្បាស់?

ពៅ  :  បាទ!ចាំច្បាស់ថ្ងៃច័ន្ទម៉ោង១រសៀល ។

វណ្ណៈ  កាលហ្នឹងបងចុះប្រតិបត្តិការណ៍ឬមួយយ៉ាងម៉េច?

ពៅ  :  កាលហ្នឹងខ្ញុំចុះទៅវៃឈ្លប ។

វណ្ណៈ  ចឹងកាលដែលបងត្រូវក្លាមចឹង  គេបញ្ជូនបងទៅព្យាបាលនៅថៃឬព្យាបាលនៅហ្នឹង?

ពៅ  :  យកព្យាបាលនៅព្រំដែនយើង ។

វណ្ណៈ  ចឹងកាលព្យាបាលនៅព្រំដែនពេទ្យមានបច្ចេកទេសឬមានថ្នាំគ្រប់គ្រាន់ទេ?

ពៅ  :  បាទ!មានគ្រប់គ្រាន់ ។

វណ្ណៈ  នៅពេលដាច់ជើងព្យាបាលអស់រយៈពេលប៉ុន្មានខែ?

ពៅ  :  ខ្ញុំព្យាបាលយូរដែលដូចជាពីរខែជាង ។

វណ្ណៈ  ចឹងនៅពេលជាមកវិញបងនៅសមរភូមិក្រោយ?

ពៅ  :  បាទ!សំរាកនៅខាងក្រោយវិញ ។

វណ្ណៈ  ចឹងសម្រាករហូត?

ពៅ  :  សម្រាករហូតអត់មានថាយើងទៅធ្វើពលកម្មអីទេ  ឬមួយឲ្យយើងទៅលើកនេះលើកនោះអត់មានទេ ។

វណ្ណៈ  ចឹងកាលហ្នឹងមានប្រាក់ខែទេ?

ពៅ  :  អត់មានប្រាក់ខែទេ  មានតែការហូបចុក ។

វណ្ណៈ  ចឹងមានចាយលុយទេ?

ពៅ  :  អត់មានទេ  តែកាលហ្នឹងមានលុយចាយហើយតែកងទ័ពមិនមានទេ  តែអ្នកនៅក្រោយមីងៗឈ្មៀតដុតធ្យូងលក់អីចឹងទៅណស់ ។

វណ្ណៈ  បាទ ។

ពៅ  :  ចឹងគាត់លក់ឲ្យថៃបានលុយខ្លះទៅ  កាលហ្នឹងលុយមានចាយ  តែចាយមិនបានទូទៅដូចយើងអីទេ អ្នកណាអត់គ្នាបើកតែរបស់ឃ្លាំងហូបទៅធម្មតាទៅមានរបប ។

វណ្ណៈ  របបទាហានមានដល់ឆ្នាំណាទៅ?

ពៅ  :  របបទាហានបើយើងនិយាយទៅទាល់តែយើងផ្តាច់ខ្លួន ។

វណ្ណៈ  ចឹងរហូតដល់ផ្តាច់ខ្លួន?

ពៅ  :  បាទ! នៅឆ្នាំ៩៦  ចុះទៅមានប្រាក់ខែមកពីណា  ទាល់តែចូលសមាហរណ៍កម្មនៅឆ្នាំ៩៦បានមានប្រាក់ខែ ។

វណ្ណៈ  គ្មានប្រាក់ខែតែមានរបបហូបចុកគ្រប់គ្រាន់?

ពៅ  :  បាទ! ត្រឹមត្រូវអត់មានខ្វះខាតទេ  មិនមែនខ្វះខាតដូចជាឆ្នាំ៧៩ទេ ។

វណ្ណៈ  ចឹងនៅពេលផ្តាច់ខ្លួននៅឆ្នាំ១៩៧៦  ពេលហ្នឹងពូសប្បាយចិត្តឬមួយមិនសប្បាយចិត្ត?

ពៅ  :  ខ្ញុំពូថាដាច់ខ្លួនឬមួយចូលសមាហរណ៍កម្មមានយន្តហោះអន្តការឬមួយយន្តហោះរដ្ឋាភិបាលចុះមកចឹងទៅខ្ញុំសប្បាយចិត្ត ។

វណ្ណៈ  ចឹងបងចង់មានសង្គ្រាមទៀតទេ?

ពៅ  :  ខ្ញុំមិនចង់មានសង្គ្រាមទេ  សង្គ្រាមគឺលំបាកណាស់  ធ្វើឲ្យខ្ញុំបែកបាក់ឪពុកម្តាយបងប្អូន ។

វណ្ណៈ  បាទ ។

ពៅ  :  សង្គ្រាមហ្នឹងបានធ្វើឲ្យខ្ញុំចង់វីរអស់ហើយដូចផេះ ។

វណ្ណៈ  បាទ ។

ពៅ  :  ចឹងខ្ញុំមិនចង់ជួបសង្គ្រាមទេ  ខ្ញុំផ្តាំកូនចៅចឹងតែម្តង  បើកូនចៅវាគេចផុតពីប្រទេសទីប៉ុន្មានក៏ទៅចុះ  ឧទាហរណ៍បើវាមានទៀត  បើកូនគេចផុតក៏គេចទៅ  តែខ្ញុំមិនចង់ឲ្យជួបទេ ។

វណ្ណៈ  ចឹងនៅក្នុងសម័យខ្មែរក្រហមឪពុកម្តាយពូស្លាប់យ៉ាងម៉េចដែរ?

ពៅ  :  ខ្ញុំនិយាយឲ្យទៀងត្រង់ទៅ  កាលដែលខ្ញុំចូលព្រៃនិងនៅពេលសមាហរណ៍កម្មហើយ នៅឆ្នាំ៩៨ខ្ញុំទៅដល់កំពត  ទៅសួររកមិនឃើញ  ពេលសួរចាស់ទុំនៅហ្នឹងក៏មិនដឹង ។

វណ្ណៈ  បាទ ។

ពៅ  :  ពេលហ្នឹងទៅរកឪពុកម្តាយបងប្អូនហើយ  ចឹងក្រោយសមាហរណ៍កម្មមកដូចជាប្រទេសជាតិយើងឯករាជ្យដូចជាសន្តិភាពចឹងណាស់ ។

វណ្ណៈ  បាទ ។

ពៅ  :  ទៅរកឪពុកម្តាយមិនបានជួប ។

វណ្ណៈ៖ ចឹងអត់ជួបសួរគេយ៉ាងម៉េច?

ពៅ ៖ ជួបតែ តាថាក្រោយឯងចូលព្រៃប្រហែលជាពីរឆ្នាំ ក្នុងឆ្នាំ៧៨ម្ដាយខ្ញុំទៅយកខ្ញុំ ទៅយកខ្ញុំនៅផ្ទះតាខ្ញុំហ្នឹង តែតាខ្ញុំថាអែងយកវាទៅណា?

វណ្ណៈ៖ បាទ ។

ពៅ ៖ ថាប្រទេសជាតិរីកវហើយ ខ្ញុំយកកូនខ្ញុំឲ្យជុំគ្រួសារខ្ញុំ ចុះអែងប្រុងទៅណាថាយកហ្នឹងវាចូលព្រៃបាត់ហើយអែងចង់ទៅណា គេចាប់វាទៅបាត់ហើយ គាត់ចង់និយាយថាពួកទ័ពព្រៃចាប់វាយកទៅបាត់ហើយ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ដល់ហើយម្ដាយខ្ញុំនិយាយប្រាប់វិញថា ចឹងខ្ញុំទៅហើយខ្ញុំមិនបាននៅទេ តា ខ្ញុំសួរថាអែងទៅណា ម្ដាយខ្ញុំថាទៅបារាំង ។

វណ្ណៈ៖ ចឹងគាត់និយាយចឹង?

ពៅ ៖ ហ្នឹងហើយ ខ្ញុំទៅជួបតាខ្ញុំកាលពីឆ្នាំ៩៨នេះណាស់ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ នៅពេលដែលខ្ញុំទៅរកតាខ្ញុំនិយាយចឹង តែខ្ញុំស៊ើបសួរទៅវាស្ងាត់ ហើយប្រទេសបារាំងប៉ុណ្ណាណឹឲ្យខ្ញុំទៅសួរឯណា ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ហើយមិនដឹងជាស៊ើបតាមណាដឹង ហ្នឹងទី១ តែបញ្ហាទី២ទៅមែនរស់ស្លាប់អីខ្ញុំមិនគិតទេ បើសិនថារស់ប្រទេសជាឯករាជ្យប៉ុណ្ណឹងហើយមិនឃើញគាត់មកស្រុក ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ឥឡូវវានៅចាលត្រង់ហ្នឹង តែគាត់នៅស្រុកគេយ៉ាងម៉េច ទោះបីថាគាត់ទៅជាជនជាតិស្អីគេក៏ដោយគាត់គួរមកលេងស្រុក ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ឬគាត់មកស៊ើបសួររកសួរអីចេះចុះឬមួយគាត់ទៅដល់ហ្នឹងដឹងតើ បងប្អូននៅហ្នឹងអាចដឹងដំណឹងអីប្រាប់មកវាចេះដែរ តែវាស្ងាត់ជ្រាប ។

វណ្ណៈ៖ ចឹងពូអត់មានបានដំណឹងអីផ្សេងទៀតទេ?

ពៅ ៖ អត់ទាំងអស់ ។

វណ្ណៈ៖ ចឹងបាត់ម្ដាយដោយគ្មានបានដំណឹង?

ពៅ ៖ អត់បានអីទាំងអស់ ឮសូរ្យដំណឹងតែបន្តិចត្រង់តា គាត់ដឹងមិញហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ពៅ ៖ ចឹងថាប្រទេសជាតិរីកវហើយខ្ញុំយកកូនខ្ញុំឲ្យនៅជុំគ្នា ខ្ញុំទៅហើយ តាខ្ញុំសួរថាទៅណា ម្ដាយខ្ញុំថាទៅបារាំងវាចេះទៅវិញ ហើយក្រោយខ្ញុំទៅជួបតាខ្ញុំមួយឆ្នាំហើយហ្នឹង ខ្ញុំមកជាន់ដីម៉ាខ្មែរវិញបានតែមួយឆ្នាំតាខ្ញុំស្លាប់ទៀត ។

វណ្ណៈ បាទ ។

ពៅ ៖ តា មាសខ្ញុំស្លាប់បណ្ដោយ ។

វណ្ណៈ គាត់ស្លាប់ដោយគាត់ចាស់?

ពៅ ៖ ស្លាប់ដោយគាត់ចាស់ ។

វណ្ណៈ ចឹងពូមានបានទៅលេងវិញទៀតទេ?

ពៅ ៖ អត់មានបានទៅលេងវិញទៀតទេ ។

វណ្ណៈ ចឹងទៅតែម្ដង?

ពៅ ៖ បាទ! ទៅតែម្ដងទេ ដល់ដំណឹងក្រោយមកពុកូនគាត់ហ្នឹងទូរស័ព្ទទៅប្រាប់ថា តាស្លាប់ហើយ ។

វណ្ណៈ ចឹងឪពុកបង?

ពៅ ៖ ទាំងអស់ហ្នឹង ។

វណ្ណៈ ចឹងបាត់ទាំងអស់?

ពៅ ៖ ទាំងម្ដាយទាំងឪពុកទាំងប្អូនហ្នឹងបីនាក់ហ្នឹង ដែលថាទៅហ្នឹងណាស់ ។

វណ្ណៈ ចឹងឥឡូវមាននៅសល់ប្អូនទេ?

ពៅ ៖ មិនមានទេ ។

វណ្ណៈ ចឹងលែងធ្វើឲ្យបងលែងនឹកស្រុកកំណើតទៀតព្រោះបាត់ឪពុកម្ដាយអស់ហើយ?

ពៅ ៖ ស្រុកកំណើតចេះតែនឹកឃើញហើយ តែជាថវិការយើងមិនសូវមានណាមួយយើងពិការផង រកមិនបានផង ដល់ចឹងនឹកឃើញថាចុះឡើងទៅខ្វះលុយខ្វះកាក់ឲ្យកូនកំពង់តែសិក្សារៀនសូត្រ ដូចនេះចេះតែទ្រាំៗទៅស្រុកកំណើតមិនថា មិននឹកនាទេ ។

វណ្ណៈ ចឹងមាននៅសល់ឪពុកមាអីទេ?

ពៅ ៖ មាន ។

វណ្ណៈ តែដូចជាចំឡែកទៅស៊ើបរកឪពុកម្ដាយនៅស្រុកមិនឃើញ?

ពៅ ៖ អត់បាត់ឈឹងបណ្ដោយ ហើយកន្លែងផ្ទះតា ដែលខ្ញុំទៅហ្នឹងផ្ទះតា គួរណាគាត់ស្គាល់ មិនថាគាត់មិនស្គាល់ទេ គាត់ចាស់ជាងយើង ។

វណ្ណៈ បាទ ។

ពៅ ៖ បើចឹងគាត់ស្គាល់ ចឹងបើគាត់ស្គាល់ដូចថាគាត់មកពីលិចនោះ មកដល់ភ្នំពេញហើយគួរតែចេះទៅរកចឹងទៅ តែវាបាត់ឈឹងថា ស្ទើរវាមិនឃើញ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ចឹងខ្ញុំចាត់ទុកថាម្ដាយខ្ញុំឪពុកខ្ញុំប្អូនប្រុសខ្ញុំ ស្លាប់ដោយមូលហេតុអីខ្ញុំមិនថា ។

វណ្ណៈ៖ តែចិត្តពូគិតថា គាត់ស្លាប់ហើយ?

ពៅ ៖ ខ្ញុំថាស្លាប់ហើយ ។

វណ្ណៈ៖ ចឹងបើនៅរស់ប្រទេសណាក៏យើងអាចដឹងដែរ?

ពៅ ៖ បាទ! កាលមុនខ្ញុំស៊ើបតាម អង្គការ អាយស៊ី អស៊ីដែរ ស៊ើបតាមអង្គការនៅស្រុកម៉ាឡេយើងហ្នឹង ។

វណ្ណៈ៖ បាទ ។

ពៅ ៖ មានខ្មែរយើងដែលនៅធ្វើការហ្នឹង សួរទៅថាយ៉ាងម៉េចកូនហ្នឹងមិនអាចទាក់ទងឪពុកម្ដាយបានទេ សួររកមិនកើតទេ ចឹងមានដឹងរឿងកិច្ចការអង្គការហ្នឹងទេ?

វណ្ណៈ៖ ខ្ញុំមិនដឹងដែរ តែបងអាចសួរបានតែទាល់តែយើងដឹងទីតាំងទំនាក់ទំនង បើបងចង់ដឹងយើងត្រូវសរសេរឈ្មោះឬអាស័យដ្ឋានចឹងទៅ ។

ពៅ ៖ ចុះបើមិនដឹងចឹង?

វណ្ណៈ៖ បងមិនដឹងចឹងពិបាករក ។

ពៅ ៖ ចឹងបានជាគេថាពិបាកណាស់ គ្រាន់តែយើងដឹងដំណឹងពីតា ពីយាយចឹងតាំងពីឆ្នាំណានោះមក ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ក្រោយមក៧៥ក្រោយមក៧៩ ដកដល់ក្រោយសមាហរណ៍កម្មនេះ ។

វណ្ណៈ៖ បាទ ។

ពៅ ៖ ហើយមកដល់៩៨បានយើងស៊ើបសួរគាត់បានជាគេនិយាយថា ពិបាករកណាស់បង រកយ៉ាងម៉េចបើបងឯងអត់មានបានដឹងថាម្ដាយទៅនៅកន្លែងណាផង មិនដឹងជារកយ៉ាងម៉េច យើងដឹងថាប្រទេសហ្នឹង តែមិនដឹងជានៅកន្លែងណា ស្រុកគេធំពិបាករកណាស់ ។

វណ្ណៈ៖ ចឹងបងបើនិយាយទៅកំសត់ណាស់ បែកឪពុកម្ដាយតាំងពីតូច ។

ពៅ ៖ បាទ ។

វណ្ណៈ៖ សង្គ្រាមចប់ហើយយើងមិនបានជួបឪពុកម្ដាយទៀត ។

ពៅ ៖ បាទ ។

វណ្ណៈ ចឹងបងនិយាយពីស្រុកម៉ាឡៃយើងវិញនៅពេលដែលធ្វើសមាហរណ៍កម្មហើយបងបានសប្បាយចិត្ត?

ពៅ : បាទ ។

វណ្ណៈ ចឹងបើបងធ្វើការប្រៀបធៀបជំនាន់ឥឡូវនិងជំនាន់ខ្មែរក្រហមចឹងគិតថាជំនាន់ខ្មែរក្រហមហ្នឹងមេដឹកនាំមានកំហុសខ្លះដែលក្នុងការដឹកនាំ?

ពៅ : មាន វាមិនអត់ទេកំហុសនោះ តែឥឡូវរដ្ឋាភិបាលសម្តេចលោកដឹកនាំបានល្អណាស់ លោកឈ្លាសវៃយើងឃើញស្រាប់ហើយ តាំងពីអត់ក្លាយជាមានផ្ទះធំមានផ្លូវមានប្រព័ន្ធខ្សែភ្លើងហើយមីនអីដោះអស់ ។

វណ្ណៈ បាទ!ចឹងមានខាងស៊ីម៉ាក់ជួយដោះ?

ពៅ : បាទ!មានអង្គការអីគេមកជួយដោះ មិនឲ្យយើងភ័យព្រួយថា ទេមិនហ៊ានទៅខ្លាចមីនអត់ទេ ។

វណ្ណៈ ចឹងដូចជាមានច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹង បងគិតថាត្រឹមត្រូវឬមួយបងគិតថាធ្វើឲ្យមានបញ្ហា?

ពៅ : អានេះបើតាមការយល់របស់ខ្ញុំ ខ្ញុំគិតថាគាត់ចាស់ហើយ ចឹងមិនដឹងជារស់បានប៉ុន្មានថ្ងៃទេប៉ុន្មានឆ្នាំទៀតទេ តាមខ្ញុំយល់ចាំកាត់អីគាត់ ។

វណ្ណៈ បាទ ។

ពៅ : អានេះជាគំនិតខ្ញុំទេ សើច.... ។

វណ្ណៈ ចឹងគិតថាពួកគាត់ចាស់ហើយ?

ពៅ : បាទ!ពួកគាត់ចាស់ហើយ ចង់ទុកឲ្យគាត់មើលឃើញថា ការតស៊ូរបស់សម្តេចទាំងបីនាក់ ការអភិវឌ្ឍន៍របស់រដ្ឋាភិបាលរាល់ថ្ងៃនេះ ថាតើលោកធ្វើល្អលោកធ្វើស្អាតហើយជឿនលឿនដល់ត្រឹមណាទៅ ទុកឲ្យគាត់មើលឃើញថា នេះហើយជាស្នាដៃគេ ។

វណ្ណៈ បាទ ។

ពៅ : មិនមែនដឹកនាំដូចជំនាន់តាឯងទេ សើច...មិនមែនដឹកនាំដូចជំនាន់អឹងឯងទេ ។

វណ្ណៈ បាទ ។

ពៅ : ដូចនេះមើលសម្តេចហ៊ុន សែន មើល ជា ស៊ីម សម្តេចហេង សំរិន មើលគាត់ដឹកនាំមកយ៉ាងម៉េច ឲ្យគាត់មើល ទោះបីខ្ញុំពិការហ្នឹងប្រាក់ខែលោកជួយទោះបីមិនគ្រប់គ្រាន់ក៏ដោយណាស់ ចឹងកាលហ្នឹងគាត់រំសាយពីកងទ័ពមកចូលសង្គមកិច្ចតែម្តង ប្រាក់ខែបាន១០០០០០រៀលដែរ ដូចថាបើកមកយើងទិញបានសៀវភៅបិចឲ្យកូនរៀនដែរ ។

វណ្ណៈ ចឹងបងកូនរៀនបានថ្នាក់ណាខ្លះហើយ?

ពៅ ៖ ខ្ញុំគិតទៅបានចូលមហាវិទ្យាល័យពីរនាក់ហើយ ។

វណ្ណៈ ចឹងឆ្នាំទីប៉ុន្មានខ្លះហើយ?

ពៅ ៖ បានឆ្នាំទី២ពីរនាក់ តែអាមួយនោះគិតទៅឆ្នាំទី៣ហើយតែអត់មានលុយឲ្យរៀន ចឹងកូនខ្ញុំក៏ចូលធ្វើការបកប្រែនៅខេត្តសៀមរាប ។

វណ្ណៈ តែបានឆ្នាំទី២ហើយ នៅពេលមានលុយអាចរៀនតទៀតបានទេ?

ពៅ ៖ បាទ ។

វណ្ណៈ ដូចខ្ញុំទើបតែរៀនចប់ផ្នែកច្បាប់ប៉ុន្មានឆ្នាំនេះទេ ឲ្យតែយើងឆ្លងកាត់បាក់ឌុបហើយ?

ពៅ ៖ បាទ! កូនទឹកឃើញថាល្អត្រង់នេះទេកូន វារៀនទៅវាចេះ វាជាប់អាហារូបករណ៍ដោយខ្លួនឯងយើងរៀនអត់មានបង់លុយ កាលទៅប្រឡងនៅប៉ោយប៉ែតឲ្យម្នាក់២០០០០០រៀល ឲ្យទៅដេកផ្ទះសំណាក់ផង ។

វណ្ណៈ ចឹងរៀនពូកែផង?

ពៅ ៖ បាទ! ចឹងនៅអាប្រុសមួយទៀតថ្នាក់ទី១២ឆ្នាំក្រោយ ។

វណ្ណៈ យើងជាឪពុកម្ដាយកូនបានរៀនចប់មានការងារធ្វើយើងអស់ព្រួយហើយ អត្ថុយដឹកតែក៏សប្បាយចិត្តដែរ?

ពៅ ៖ និយាយថាសប្បាយៗហើយតែរាល់ថ្ងៃនេះ រាល់ខែនេះឥឡូវគិតយ៉ាងម៉េច ក្នុងមួយខែ៣០ទៅ៤០ដុល្លាចឹងមួយឆ្នាំអស់ប៉ុន្មាន ។

វណ្ណៈ ចឹងទោះបីយើងអត់បង់ថ្លៃសាលា យើងត្រូវចំណាយទៅលើថ្លៃហូបចុក?

ពៅ ៖ បាទ!ចំណាយទៅលើថ្លៃហូបចុកនិងផ្ទះជួលហ្នឹង ទី១រៀននៅទឹកថ្លាយើងនេះអាហ្នឹងសកលវិទ្យាល័យឬមហាវិទ្យាល័យ ។

វណ្ណៈ នៅក្នុងភ្នំពេញសាលាច្រើនដែរ នៅក្នុងភ្នំពេញច្រើនតែមហាវិទ្យាល័យ ។

ពៅ ៖ សាលាទឹកថ្លានៅជិតគល់ស្ពានជិះមកហ្នឹង នៅបន្ទាយមានជ័យហ្នឹង ។

វណ្ណៈ អរនៅហ្នឹងទេ កន្លែងហ្នឹងមហាវិទ្យាល័យខ្ញុំធ្លាប់មកចែកសៀវភៅដែរ ។

ពៅ ៖ បាទ ។

វណ្ណៈ ចឹងចាំខ្ញុំយកសៀវភៅឲ្យកូនបងរៀន ព្រោះអាចចេញនៅពេលប្រឡងដែរ សៀវភៅកម្ពុជាប្រជាធិបតេយ្យ ។

ពៅ ៖ ចឹងសៀវភៅយ៉ាងម៉េច ។

វណ្ណៈ ចាំបន្តិចខ្ញុំឲ្យទៅបង ចឹងខ្ញុំសុំបញ្ចប់សំនួររបស់បង តើបងមានអីចង់និយាយបន្ថែមទៀតទេ ។

ពៅ ៖ ខ្ញុំដូចជាអត់មានពាក្យអីត្រូវនិយាយទៀតផង ។

*វណ្ណៈ៖  បើដូច្នេះ ខ្ញុំអរគុណបងច្រើន ។*

*ពៅ ៖  បាទ! សុខសប្បាយ ។*

**«ចប់»**